ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលក្រុងសិរីសោភ័ណ
គណៈកម្មាធិការលទ្ធកម្ម
លេខ : ០៩៧.សជណ អល

សេចក្តីជូនដំណឹង
ស្តីពី
ការអញ្ជើញចូលរួមពិគ្រោះថ្លៃការងារជួសជុលផ្លូវដី

រដ្ឋបាលក្រុងសិរីសោភ័ណ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋបាលក្រុងសិរីសោភ័ណ នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារសាងជួសជុលផ្លូវដី ប្រវែង ៥៨០មែត្រ ទទឹង ៥មែត្រ ចំនួន០១កន្លែង នៅភូមិ៤ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

រដ្ឋបាលក្រុងសិរីសោភ័ណ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋាន ផ្លូវជាតិលេខ ៥៦Aភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិសីសោភ័ណ ចាប់ពីថ្ងៃទី ១៥ ខែមិថុនាឆ្នាំ ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ. ០៨៩ ៣៤ ៩៩ ៩៤) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ៩:00នាទីព្រឹក ។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:00នាទីព្រឹក ថ្ងៃទី ៣០ខែ មិថុនា ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ធ្វើនៅ សិរីសោភ័ណ, ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦

ប្រធានគណៈកម្មាធិការលទ្ធកម្ម

ចម្លងជូន ៖
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារកាលប្បវត្តិ

តំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ងង់តម្លៃ (ពិគ្រោះថ្លៃ សំណង់) ទំព័រ 164/241